# សិលាចារឹកភូមិសំបួរ K.៦៦៤

## ១- ព័ត៌មានទូទៅ

សិលាចារឹកមួយផ្ទាំងនេះ បានរកឃើញនៅទួលស្លី ភូមិសំបួរ អតីតស្រុកភ្នំពេញ ខេត្តកណ្ដាល បច្ចុប្បន្នត្រូវនឹងភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ពុំមានឯកសារបញ្ជាក់អំពីទីតាំង និងបុរាណវត្ថុផ្សេងៗទៀត នៅទីតាំងរកឃើញនោះឡើយ ពោលគឺមានត្រឹមរបាយការណ៍យកសិលាចារឹកនេះ ចូលមកសារមន្ទីរជាតិភ្នំពេញ កាលពីឆ្នាំ១៩៣០ ប៉ុណ្ណោះ។ តាមរយៈគេហទំព័រផែនទីបុរាណដ្ឋាននៃប្រទេសកម្ពុជា (CISARK) សន្និដ្ឋានថាសិលាចារឹកនេះរកឃើញនៅតាំង វត្តសំបួរមាស ដែលនៅទីនោះមានបំណែកបល្ល័ង្កមួយ ដើងទម្រថ្មភក់ និងគ្រុឌ ព្រមទាំងសិលាចារឹកមួយផ្ទាំងនេះ។[1]

ក្នុងឆ្នាំ១៩៥៣ លោក ហ្សក សេដេស បានសិក្សានិងចុះផ្សាយអត្ថបទសិលាចារឹកនេះ នៅក្នុងសៀវភៅសិលាចារឹកនៃប្រទេសកម្ពុជា (Inscriptions du Cambodge) ក្បាលទី៥ របស់លោក។ ចំណែកលោក ហ្វីលីព ជេន្នើរ ក៏បានសិក្សាអត្ថបទសិលាចារឹកនេះផ្សាយជាភាសាអង់គ្លេសដែរ ដែលការសិក្សារបស់លោកពឹងផ្អែកសំខាន់លើឯកសាររបស់លោកសេដែស។

អត្ថបទសិលាចារឹកនេះ ចារនៅលើថ្មស្រទាប់ ដែលជាប្រភេទថ្មនិយមប្រើនៅសម័យអង្គរ និងរចនារូបរាងបែបសទ្ទឹកសីមា ប៉ុន្តែការរចនានោះពុំបានល្អស្អាតប៉ុន្មានទេ។ ចំពោះ ការចារអក្សរវិញ មានការផ្ទាត់ដាច់ផ្ទៃថ្មជាច្រើនអន្លើផង។ អត្ថបទមានចំនួន១៤ បន្ទាត់ សរសេរជាភាសាខ្មែរបុរាណសម័យមុនអង្គរ ពុំមានចុះកាលបរិច្ឆេទឡើយ ប៉ុន្តែតាមទម្រង់តួអក្សរ ឬបុរាណលេខន៍ វាគួរតែស្ថិតនៅក្នុងរវាងស.វ.ទី៧-៨។ អត្ថន័យសំខាន់នៃអត្ថបទនេះ គឺជាបញ្ជីខ្ញុំបម្រើ ដីស្រែ និងគោ ជាបុណ្យរបស់ម្រតាញកុមារស្វាមី ដែលថ្វាយចំពោះប្រាសាទព្រះគម្តែងអញតិលកេសូរ។ ចំពោះអ្នកបម្រើភេទស្រី យើងឃើញអ្នកខ្លះមានកូន និងចៅមកធ្វើការជាមួយផង។

[1] https://cisark.mcfa.gov.kh/core/showsite.php?id=1388&keyword=

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

១- អំនោយ៑ម្រតាញ៑កុមារស្វាមិព្វតវ្រះកម្រតាង៑អញ៑តិល

២- កេគ្វរ៑·តាញ៑គិ◌ុតយជមានតវ្រះក្វោញ៑បោញ៑·ក្វោញ៑សំរោក៑

៣- ឯការលិ[1]·តាង៑កន្មេង៑·គេយជមានវ្រះគេចុះតង៉ៃវ្រហ្ម

៤- ក្ញុំវ្រះតឃោទវាអំវិលគាខ·វាធតិ·វាករិក្វា·វាត្មញ៑·

៥- វាលទុ·វាមណ្ឌា[2]·វាត្វោ-◌ិ·វាកុកះ·វាអំបិក៑·វាត្យោន៑·វា

៦- សំវេរ៑·វា(ត្មា/ស្មា)ស៑·វាត្វៃ·កុនយនី១កោនិកុ៤ថៅកុ២

៧- កុជំវុលី១កោនិកុ៤កុចន្ទ្រលេខ១កោនិកុ៤កុ-

៨- ក១កោនិកុ៦[3]ថៅកុ៤កុអ្នង៑១កោនិកុ៤កុកិសរិ(១)

៩- កោនិកុ៤កុមញ្ជរី១កោនិកុ២កុផ្នហិសេង៑១កោ(និ)

១០- កុ២កុក្រមវី១កោនិកុ២កុកត្តិលី១កុស្រី១កុតិ(លិ)

១១- វា[4]ច្កបិ១កុកុកះ១កុរំនោចិវ្រះ១ក្ញុំប្រទាន(កុ-)

១២- ន្ទហ្ហូរូ១កុវង្គគ្រីយ១ស្រេសន្រេ៧ត្មុរិ៨០[5]

១៣- (ស្រេ)[6]មានិជាហ្វព្វស្តុកិស្វាង៑[7] ទ្រោង៑ច្បវ៑[8]វេរិស[ន្រេ]

១៤- --វះវុនិស្រេវ្រៃយិក្រាយិស្រេប្រសានិ--

---

[1] លោក សេដេស (១៩៥៣) អានជា «ចំការលិ»។

[2] លោក សេដេស (១៩៥៣) អានជា «វាមទ្ធា»។

[3] លោក សេដេស (១៩៥៣) អានជា «៥»។

[4] លោក សេដេស (១៩៥៣) ពុំអានពាក្យនេះ។

[5] លោក សេដេស (១៩៥៣) អានជា «២០»។

[6] លោក សេដេស (១៩៥៣) ពុំអានពាក្យនេះ។

[7] លោក សេដេស (១៩៥៣) អានជា «-ង៑ថ្វាង៑»។

[8] លោក សេដេស (១៩៥៣) អានជា «ព្រៀង៑ច្បរ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## ៣- អត្ថបទប្រែសម្រួល

(១-២) អំណោយ(/តង្វាយ)របស់ម្រតាញកុមារស្វាមី (ថ្វាយ)ចំពោះព្រះគម្តែងអញ តិលកេស្វរ។

(២-៣) អ្នកដែលជាយជមានចំពោះព្រះគឺក្ញោញបោញ ក្ញោញសំរោកឯការលី (និង)តាងកន្ទេង។ អ្នកទាំងនេះគឺជាយជមានព្រះ និងជាអ្នកកត់ត្រា(នា)ថ្ងៃសីល។

(៤-១១) អ្នកបម្រើព្រះ ដ៏ជាបុរស(មាន) វាអំពិលសាខ វាធត វាករក្វា វាត្មញ វាលទុ វាមណ្ឌា វាត្វោ- វាកុកះ វាអំបិក វាត្បោន វាសំវេរ វាគ្មាស វាត្វៃ (និងជាស្រ្តីមាន)កុនយនី១ កូន៤ និងចៅ២ កុជំរុលី១ កូន៤ កុចន្ទ្រលេខ១ កូន៤ កុ-ក កូន៦ និងចៅ៤ កុអ្នង១ កូន៤ កុកិសរ១ កូន៤ កុមញ្ជរី១ កូន២ កុផ្ទហសេង១ កូន២ កុក្រមរី១ កូន២ កុកត្តិលី១ កុស្រី១ កុតិលិ-១ វាច្កុប១ កុកុកះ១ កុរំនោចវ្រះ១។

(១១-១២) អ្នកបម្រើជាអំណោយ (មាន) កុ--ន្ទហ្គរូ១ កុរង្គស្រីយ១។

(១២-១៤)ស្រែ៧សន្រែ គោ៨០ ស្រែដែលជារនោងស្តុកស្វាងនិងច្បារ២សន្រែ --- (មានស្រែនៅ--)វះវុន ស្រែវ្រៃក្រាយ ស្រែប្រសាន--។

## ៤- ពន្យល់ពាក្យ

| | |
|---|---|
| **ម្រតាញ** | ឋានន្តរនាមរបស់មន្រ្តីព្រះមហាក្សត្រឬព្រាហ្មណ៍ថ្នាក់ខ្ពស់នាសម័យមុនអង្គរ។ |
| **វ្រះកម្រតាងអញ** | ឋានន្តរនាមអាទិទេពឬព្រះមហាក្សត្រនាសម័យមុនអង្គរ។ ពាក្យនេះត្រូវនឹងពាក្យទំនើបថា «ព្រះគម្តែងអញ» មានន័យថា «លោកជាអម្ចាស់នៃខ្ញុំ»។ |
| **តិលកេឝ្វរ** | (សំ. តិលក = ចឹម + ឦឝ្វរ = ទេព) ទេពនៃតិលក, ជាព្រះនាមម្យ៉ាងរបស់ព្រះឥស្វរ។ |
| **តាញ** | ជាឋានន្តរនាមសម័យមុនអង្គរ។ ក្នុងសិលាចារឹកនេះ សំដៅដល់អ្នកដែលជាយជមានចំពោះព្រះ។ |

អត្ថបទដោយៈ ហ៊ុន ឈុនតេង

| | |
|---|---|
| យជមាន | អ្នកធ្វើយជ្ញ អ្នកធ្វើពិធីសក្ការបូជា អ្នកមានធនបានរៀបចំពិធីបូជា។ |
| ក្មោញ | មេ ប្រធាន មេក្មោង។ |
| កន្មេង | ក្មេង។ |
| ចុះ | កត់ត្រា ចុះបញ្ជី។ |
| តងៃ | ថ្ងៃ។ |
| តងៃវ្រះ | ថ្ងៃសីល។ |
| ក្ញុំ | អ្នកបម្រើ។ |
| ឃោទ | (សំ.) ជាឋានន្តរនាមសម្គាល់បុរស មនុស្សប្រុសពេញកម្លាំង។ |
| វា | ឋានន្តរនាមសម្គាល់មនុស្សប្រុស។ |
| កុ | ឋានន្តរនាមសម្គាល់មនុស្សស្រី។ |
| ស្រេ | ស្រែ។ |
| សន្រេ | ខ្នាតផ្ទៃស្រែ។ |
| ទ្រាង | ទាំង រួមទាំង និង។ |
| ច្បារ់ | ច្បារ។ |
| វ្រៃ | ព្រៃ។ |

## ឯកសារយោង

Cœdès, George. (1953). Stele de Saṃbuor. In *Inscription du Cambodge* (Vol. V, pp. 69-70). Paris: Editions de Boccard.

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព




សិលាចារឹកភូមិសំបួរ K.៦៦៤ (រូបថត៖ EFEO_ CAM19762-1)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សំណៅផ្តិតសិលាចារឹកភូមិសំបួរ K.៦៦៨ (រូបថត៖ EFEO_ CAM17102-1)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង




ខ្ទមបារមីលោកយាយម៉ៅ ជាទីមានថ្មស្រទាប់បីសន្ទឹក (រូបថត៖ ហ៊ុន ឈុនតេង)



ថ្មស្រទាប់ទាំងបីសន្ទឹក មានមួយផ្ទាំងជាថ្មទ្រនាប់ជណ្ដើរប្រាសាទ (រូបថត៖ ហ៊ុន ឈុនតេង)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



ព្រះសុគន្ធកុដិវត្តសំបួរមាស មានតម្កល់សិលាចារឹកចម្លង (រូបថតៈ ហ៊ុន ឈុនតេង)



ព្រះសុគន្ធកុដិវត្តសំបួរមាស មានតម្កល់សិលាចារឹកចម្លង (រូបថតៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង




ផ្ទាំងសិលាចារឹក K.៦៦៤ ចម្លងថ្មី (រូបថតៈ ហ៊ុន ឈុនតេង)



ព្រះវិហារវត្តសំបួរមាស (រូបថតៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង